**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៤ សសរ

# សេចក្តីសម្រេច

## ស្តីពីការបង្កើតគណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៧៥ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការកែសំរួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានឃើញអនុក្រឹត្យលេខ៥១៤ អនក្រ-តត ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការនីតិកម្ម និងបច្ចេកទេសកិច្ចការព្រំដែន

-បានឃើញអនុក្រឹត្យលេខ៥១៥ អនក្រ-តត ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការត្រួតពិនិត្យ ដោះស្រាយបាតុភាព និងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនកម្ពុជាជាមួយប្រទេសជិតខាង

-បានឃើញសេចក្តីសំរេចលេខ១៩ សសរ ចុះថ្ងៃទី៩ ខែមិនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-វៀតណាម

-យោងតាមតំរូវការចាំបាច់

## សំរេច

**ប្រការ១** : បង្កើតគណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាមដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **វ៉ា គឹមហុង** ទេសរដ្ឋមន្ត្រី ទីប្រឹក្សារាជរដ្ឋាភិបាលទទួលបន្ទុកកិច្ចការព្រំដែន ប្រធានគណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-វៀតណាម ប្រធាន

២-ឯកឧត្តម **ឡុង វិសាលោ** រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៣-ឯកឧត្តម **ម៉ិន សម** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៤-ឯកឧត្តម **ហួន សាម៉ាង** អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៥-ឧត្តមសេនីយ៍ឯក **ឈុំ សុជាត** នាយរងសេនាធិការ និងជានាយកទីចាត់ការការងារព្រំដែន ក្រសួងការពារជាតិ សមាជិក

៦-ឯកឧត្តម **ឡាំ ជា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៧-លោកជំទាវ **កុយ ពិសី** លេខាធិការ នៃលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៨-ឯកឧត្តម **ម៉ិន ហ៊ាន** អគ្គនាយកកិច្ចការបច្ចេកទេស និងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍សំរបសំរួលការងារទំនប់ប្រឡាយតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ឡាវ និងថៃ ក្រសួងធនធានទឹក និងឧតុនិយម សមាជិក

៩-ឧត្តមសេនីយ៍ឯក**ចាន់ អ៊ាន** ប្រធាននាយកដ្ឋានកណ្តាល ក្រសួងមហាផ្ទៃ សមាជិក

១០-ឧត្តមសេនីយ៍ឯក**ទេព ចំរើន**ប្រធាននាយកដ្ឋានភូមិសាស្ត្រ ក្រសួងការពារជាតិ សមាជិក

១១-ឯកឧត្តម **អភិបាលខេត្ត** កំពង់ចាម សមាជិក

១២-ឯកឧត្តម **អភិបាលខេត្ត** ស្វាយរៀង សមាជិក

១៣-ឯកឧត្តម **អភិបាលខេត្ត** ព្រៃវែង សមាជិក

១៤-ឯកឧត្តម **អភិបាលខេត្ត** កណ្តាល សមាជិក

| | | |
|---|---|---|
| ១៥-ឯកឧត្តម **អភិបាលខេត្ត** | តាកែវ | សមាជិក |
| ១៦-ឯកឧត្តម **អភិបាលខេត្ត** | កំពត | សមាជិក |
| ១៧-ឯកឧត្តម **អភិបាលខេត្ត** | ក្រចេះ | សមាជិក |
| ១៨-ឯកឧត្តម **អភិបាលខេត្ត** | មណ្ឌលគិរី | សមាជិក |
| ១៩-ឯកឧត្តម **អភិបាលខេត្ត** | រតនគិរី | សមាជិក |
| ២០-ឧត្តមសេនីយ៍ **មេបញ្ជាការ** | យោធភូមិភាគ១ | សមាជិក |
| ២១-ឧត្តមសេនីយ៍ **មេបញ្ជាការ** | យោធភូមិភាគ២ | សមាជិក |
| ២២-ឧត្តមសេនីយ៍ **មេបញ្ជាការ** | យោធភូមិភាគ៣ | សមាជិក |
| ២៣-ឧត្តមសេនីយ៍ទោ **សេខ សារី** | នាយសេនាធិការ និងជានាយការិយាល័យការពារព្រំដែនកងទ័ពជើងគោក ក្រសួងការពារជាតិ | សមាជិក |
| ២៤-លោក **អ៊ិត សុទ្ធា** | ប្រធាននាយកដ្ឋានភូមិសាស្ត្រ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២៥-លោក **ឡាយ ចោមារិទ្ធ** | ប្រធាននាយកដ្ឋានកិច្ចការនយោបាយ ក្រសួងមហាផ្ទៃ | សមាជិក |
| ២៦-ឧត្តមសេនីយ៍ត្រី **ពេជ្រ ជីវ័ន្ត** | ប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក ក្រសួងមហាផ្ទៃ | សមាជិក |
| ២៧-លោក **ឃូ ពៅជ្រមោលី** | អនុប្រធាននាយកដ្ឋានច្បាប់និងកុងស៊ុលក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

**ប្រការ២** : គណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម អាចបង្កើតអនុគណៈកម្មការបច្ចេកទេសចំរុះ ក្រុមប្រតិបត្តិការចំរុះ និងក្រុមបច្ចេកទេសចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោក សំរាប់ធ្វើជាសេនាធិការ ។

**ប្រការ៣** : គណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម មានភារកិច្ចដូចតទៅ :

-អនុវត្តឱ្យបានសំរេចជាស្ថាពរនូវសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥ រវាងព្រះរាជាណាចក្រកម្ពុជា និង

សាធារណរដ្ឋសង្គមនិយមវៀតណាម

-រៀបចំចាត់ចែងបែបបទផ្លូវច្បាប់និងបច្ចេកទេសសំរាប់ការងារខ័ណ្ឌសីមានិងបោះបង្គោលព្រំដែន

-រៀបចំចាត់ចែងតួនាទី ភារកិច្ច និងសមាសភាពរបស់អនុគណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែន ក្រុមប្រតិបត្តិការចំរុះ និងក្រុមបច្ចេកទេសចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនលើដីជាក់ស្តែង

-ធ្វើការត្រួតពិនិត្យ ដោះស្រាយបញ្ហា និងឯកសារនានា ដែលក្រុមប្រតិបត្តិការ និង ក្រុមបច្ចេកទេសរាល់វែងជួបប្រទះ លើដីជាក់ស្តែង

-ធ្វើរបាយការណ៍តាមតំណាក់កាលនីមួយៗ អំពីសភាពការណ៍នៃការដោះស្រាយ និងការកំណត់ខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនលើដីជាក់ស្តែង ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនសំរាប់រាយការណ៍ជូនគណៈរដ្ឋមន្ត្រី ។

**ប្រការ៤** : គ្រប់សមាជិកនៃគណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោក ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន ។

**ប្រការ៥** : គណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោក មានទីស្នាក់ការនៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ៦** : គណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោក នឹងត្រូវរំសាយទៅវិញនៅពេលណាដែលការងារអនុវត្តសន្ធិសញ្ញាដូចក្នុងប្រការ៣ ត្រូវបានចប់សព្វគ្រប់ ។

**ប្រការ៧** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួង-ស្ថាប័ន អង្គភាពសាមី និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៧

-ឯកសារកាលប្បវត្តិ